# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

**CAMBODIA WATCHDOG COUNCIL INTERNATIONAL**

CWC-International, # Havreveien 94, 4635 Kristiansand City, Norway, Tel: +4790818257/ +4799489347/E-mail: cwci_secretariat@yahoo.com/ cwci@start.no


---

គ្រីស្ទានសាន់ ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៩

## សេចក្តីថ្លែងការណ៍

រដ្ឋាភិបាលកម្ពុជា បញ្ជូនលោក វ៉ា គឹមហុង ប្រធានគណៈកម្មាធិការព្រំដែន ដ៏អសមត្ថភាពដើម្បីទៅបំភ្លឺនៅចំពោះមុខ អ្នកតំណាងរាស្ត្រក្នុងរដ្ឋសភាជាតិ កាលពីថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៩ ប៉ុន្តែលោក មិនបានឆ្លើយបំភ្លឺនូវសំណួរទាំងឡាយ ដែលអ្នកតំណាងរាស្ត្រ សុន ឆ័យ នៃគណបក្ស សម រង្ស៊ី បានដាក់ជូននោះទេ។ លោក បានព្យាយាមឆ្លើយពង្វាង ដោយបកស្រាយតែទៅលើច្បាប់ព្រំដែន បញ្ហាបច្ចេកទេស និងបញ្ហាផ្សេងៗមួយចំនួនទៀត មកជំនួសវិញ។ ក្នុងខណៈពេលនោះ អ្នកតំណាងរាស្ត្រ សុន ឆ័យ ក៏បានព្យាយាមសុំឱ្យលោក វ៉ា គឹមហុង ឆ្លើយឱ្យចំសំណួរ ប៉ុន្តែត្រូវបានប្រធានរដ្ឋសភា លោក ហេង សំរិន ហាមឃាត់ និងបំបិទសិទ្ធិរបស់លោក សុន ឆ័យ តាមរយៈការគោះញញួរ និងបិទមេក្រូហ្វូន ដើម្បីទុកឱកាសឱ្យលោក វ៉ា គឹមហុង និយាយដោះសាររហូតចប់កិច្ចពិភាក្សា។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋខ្មែរទាំងក្នុង និងក្រៅប្រទេស មានការសោកស្តាយ និងខកចិត្តជាខ្លាំងចំពោះការបំភ្លឺរបស់លោក វ៉ា គឹមហុង នៅក្នុងរដ្ឋសភា និងទង្វើរបស់រដ្ឋាភិបាលកម្ពុជា ដែលគ្មានឆន្ទៈការពារបូរណភាពទឹកដី តែផ្ទុយទៅវិញបណ្តោយឱ្យប្រទេសជិតខាងឈ្លានពានទឹកដីខ្មែរ ព្រមទាំងព្យាយាមការពារបរទេស ក្នុងការលេបយកទឹកដីខ្មែរទៀត។ ជាក់ស្តែងថ្មីៗនេះ **រដ្ឋាភិបាលបានប្រើប្រាស់ប្រព័ន្ធតុលាការរបស់ខ្លួននៅខេត្តស្វាយរៀង ចាប់ប្រជាពលរដ្ឋ ដែលបាត់បង់ដីស្រែចំការដោយការរំលោភយកពីសំណាក់ប្រទេសវៀតណាម ដាក់ពន្ធនាគារ ក្រោមលេសថាប្រជាពលរដ្ឋទាំងនោះ ចូលរួមដកបង្គោលតម្រុយព្រំដែនកម្ពុជា-វៀតណាម**។ នេះសរបញ្ជាក់កាន់តែច្បាស់ថា រដ្ឋាភិបាលកម្ពុជា កំពុងបំរើនយោបាយឱ្យប្រទេសវៀតណាម ដោយដាក់ទណ្ឌកម្មមកលើប្រជាពលរដ្ឋខ្មែរខ្លួនឯង ដើម្បីផ្គាប់ចិត្តរដ្ឋាភិបាលក្រុងហាណូយ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាថ្កោលទោសយ៉ាងដាច់អហង្កា ដល់រដ្ឋាភិបាលកម្ពុជា ក្នុងការបោះបង្គោលព្រំដែនកម្ពុជា-វៀតណាម ដែលធ្វើឱ្យបាត់បង់ដីស្រែចំការរបស់ប្រជាពលរដ្ឋខ្មែរនៅតាមបណ្តោយព្រំដែន (ព្រំដែនគោក) ចន្លោះពី ៤០០០ ទៅ ៦០០០ គ.ម.ក្រឡា។

រដ្ឋាភិបាលកម្ពុជា ត្រូវបញ្ឈប់កាប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីចាប់ខ្លួនប្រជាពលរដ្ឋរងគ្រោះ ដាក់ពន្ធនាគារ និងត្រូវដោះលែង ជនរងគ្រោះទាំងពីររូបគឺ **លោក ព្រំ ជា** និង **អ្នកស្រី មាស ស្រី** ឱ្យមានសេរីភាពដោយឥតលក្ខខណ្ឌ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ប្រធាន**

**ម៉ែន ណាត**